# អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ

ជួយស្ត្រីដើម្បីអោយស្ត្រីអាចជួយខ្លួនឯង

CAMBODIAN WOMEN'S CRISIS CENTER (CWCC)

*helping women help themselves*

## ដំណឹងជ្រើសរើសបុគ្គលិកបំរើការងារមិនពេញម៉ោង
## តួនាទី៖ បុគ្គលិកអង្កេត/ជំនួយការផ្នែកច្បាប់

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ មិនរកប្រាក់ចំណេញ ដែលចាប់ផ្តើមប្រតិបត្តិការតាំងពីឆ្នាំ១៩៩៧ ហើយនៅតែបន្តពង្រីកសេវាកម្មរបស់ខ្លួន ដើម្បីជួយស្ត្រី និងកុមារដែលជាជនរងគ្រោះដោយអំពើហិង្សា ការរំលោភ និងការជួញដូរ។ បេសកកម្មរបស់អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) គឺពង្រឹងសិទ្ធិអំណាចដល់ស្ត្រី និងកុមារីឲ្យទាមទារសិទ្ធិជាសកលរបស់ខ្លួន ដើម្បីទទួលបាននូវសុវត្ថិភាពផ្ទាល់ខ្លួន និងអាចចូលរួមដោយស្មើភាពគ្នាក្នុងការងារសហគមន៍ សង្គមស៊ីវិល ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងចូលរួមក្នុងសកម្មភាពនយោបាយ សង្គម និងវប្បធម៌ តាមរយៈផែនការយុទ្ធសាស្ត្រនៃកម្មវិធីការទប់ស្កាត់ ការការពារ ការតស៊ូមតិ និងការអភិវឌ្ឍន៍អង្គការ។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) ត្រូវការជ្រើសរើសបុគ្គលិកអង្កេត/ជំនួយផ្នែកច្បាប់ ចំនួន១នាក់ បំរើការងារមិនពេញម៉ោង នៅការិយាល័យភ្នំពេញ។

**ការទទួលខុសត្រូវ:**

- ជួយសំភាសន៍អតិថិជន និងស្វែងរកសេវាសមរម្យជូនអតិថិជន
- ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់អតិថិជន
- ចុះអង្កេត និងប្រមូលព័ត៌មាន និងរៀបចំរក្សាទុកឯកសាររបស់អតិថិជន
- ជួយរៀបចំសំណុំរឿងជូនមេធាវី
- នាំអតិថិជនទៅចូលរួមសវនាការនៅតុលាការ
- សហការជាមួយអាជ្ញាធរ និងអង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធដើម្បីជួយអតិថិជន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនប្រធានកម្មវិធី

**លក្ខណៈសម្បត្តិជ្រើសរើស**

- ជាសិស្សឆ្នាំទី៣ផ្នែកច្បាប់ ឬមានសញ្ញាប័ត្រផ្នែកច្បាប់កាន់តែល្អ
- ត្រូវមានចំណេះដឹងផ្នែកច្បាប់ខ្លះៗ
- ចេះភាសារអង់គ្លេសអាចប្រើការបាន
- មានឆន្ទៈជួយស្ត្រី និងកុមារជាជនរងគ្រោះ
- មានការតាំងចិត្តខ្ពស់ក្នុងការអនុវត្តការងារ និងមានការទទួលខុសត្រូវ
- មានភាពរួសរាយរាក់ទាក់ និងមានកិច្ចសហការល្អនៅក្នុង និងក្រៅអង្គការ
- ត្រូវចេះកុំព្យូទ័រ Microsoft Word និង Microsoft Excel

**ប្រាក់បៀវត្ស២០០ដុល្លារ ក្នុង១ខែ និងមានប័ណ្ណធានារ៉ាប់រង ប.ស.ស ។**

បេក្ខជនមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបនិងឯកសារពាក់ព័ន្ធ មកអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ដែលមានអស័យដ្ឋាន ផ្ទះលេខ ៤២F ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ ០២៣ ៩៨៧ ១៥៨ ឬតាមរយៈអ៊ីមែល H0hr@cwcc.org.kh ។ ឈប់ទទួលពាក្យនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣។